អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៣ ចេញផ្សាយ ខែមីនា ឆ្នាំ២០២២

## ភាពខុសគ្នារវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ

មុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច បានបែកចែកយ៉ាងច្បាស់ និងខុសពីគ្នា ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដើម្បីជៀសវាងការអនុវត្តស្ទួនគ្នា និងក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

### មុខងារនៃសវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ បំពេញមុខងារជាសេនាធិការចំណុះផ្ទាល់រដ្ឋមន្ត្រី-ក្រសួង ប្រធានស្ថាប័ន ដោយទទួលបន្ទុកអនុវត្តភារកិច្ចស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ស្របជាមួយគ្នានេះ អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. បំពេញមុខងារជាសេនាធិការជូនក្រុមប្រឹក្សា អ.ស.ហ. និងប្រធាន អ.ស.ហ. លើការងារសវនកម្ម ដោយមានបេសកកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងតាមរយៈការតាមដាន និងការត្រួតពិនិត្យប្រកបដោយជំនាញវិជ្ជាជីវៈ ក្រមសីលធម៌ ឯករាជ្យភាព សុចរិតភាព ការទទួលខុសត្រូវនិងអភិវឌ្ឍន៍មុខងារសវនកម្មផ្ទៃក្នុង ព្រមទាំងបណ្តុះបណ្តាលអង្គភាពក្រោមឱវាទពាក់ព័ន្ធនឹងមុខងារសវនកម្មផ្ទៃក្នុង។

### មុខងារនៃអធិការកិច្ចហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋនៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីតិបុគ្គលសាធារណៈ និងឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំរបាយការណ៍លទ្ធផលអធិការកិច្ចហិរញ្ញវត្ថុប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

អធិការកិច្ចហិរញ្ញវត្ថុ មានបេសកកម្មពិនិត្យលើអនុលោមភាព សមិទ្ធកម្មនៃការគ្រប់គ្រង និងការអនុវត្តកិច្ចប្រតិបត្តិការហិរ-ញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដោយផ្អែកលើហានិភ័យ ករណីសង្ស័យ បណ្តឹងតវ៉ា និងបណ្តឹងបរិហារ ក្នុងគោលដៅចូលរួមធានាការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ធានាការគោរពនិងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ, កំណត់អំពើបំពានហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋតាមរយៈការចាត់វិធានការឱ្យទទួលខុសត្រូវ, បង្ការ និង/ ឬចាត់វិធានការចំពោះការប្រព្រឹត្តកំហុសដោយចេតនា ឬអចេតនាលើការគ្រប់គ្រង និង/ ឬការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ធានាបូរណភាព និងសង្គតិភាពនៃព័ត៌មាន និងទិន្នន័យហិរញ្ញវត្ថុសម្រាប់ការចូលរួមរៀបចំថវិកា និងទូទាត់ប្រចាំឆ្នាំ។

ជារួម សវនកម្មផ្ទៃក្នុងដើរតួនាទីត្រួតពិនិត្យផ្ទៃក្នុង តាមបណ្តាក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន អង្គភាពរាជធានី ខេត្ត។ អធិការកិច្ចហិរញ្ញវត្ថុដើរតួនាទីពិនិត្យផ្ទៃក្រៅតាមបណ្តាក្រសួង ស្ថាប័ន សហគ្រាសសាធារណៈដែលបានកំណត់ក្នុងច្បាប់បទដ្ឋានគតិយុត្តជាធរមាន។

***អត្ថបទ៖*** *លោក* ***ថន សំណាង***

***ឯកសារយោង៖***

*១-អនុក្រឹត្យស្តីពីក្របខណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច*

*២-អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ*